មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៏កសិកម្មកម្ពុជា (អង្គការសេដាក) និងបណ្តាញកសិករ និងធម្មជាតិ (FNN) សហការជាមួយសមាគមកសិករអាស៊ាន (AFA) បានរៀបចំធ្វើសន្និសីទកាសែតមួយស្តីអំពី **ពាណិជ្ជកម្មកសិកម្មថ្នាក់ជាតិ** នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៨ នៅការិយាល័យអង្គការសេដាក ក្រុងភ្នំពេញ។ អ្នកចូលរួមចំនួន ២៦ នាក់ រួមមានតំណាងកសិករ តំណាង AFA និងអ្នកកាសែតជាតិ អន្តរជាតិ តំណាងឱ្យស្ថាប័ន កាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍ ចូលរួមនៅក្នុងសន្និសីទកាសែតនេះ។

នៅក្នុងសន្និសីទនោះកសិករបានលើកឡើងថា ដើម្បីឱ្យកសិករទទួលបានផលប្រយោជន៍ពីពាណិជ្ជកម្ម កសិកម្ម ពួកគេត្រូវតែមានសមត្ថភាពចំបងក្នុងការចូលរួម និងប្រកួតប្រជែងលើទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ ប្រកបដោយប្រសិទ្ធិភាព។ ដូច្នោះហើយយើងជឿជាក់ថា សំលេងនៃគោលនយោបាយ កសិកម្មគួរតែជាមូលដ្ឋាននៃគោលនយោបាយពាណិជ្ជកម្មជាតិរបស់ប្រទេស ។ ចំពោះករណីនេះ យើងកំពុងតែសំដៅទៅរកអានុសាសន៏ជាបន្តបន្ទាប់ ដែលមានគោលបំណងកែលំអផលិតភាពកសិករក្រីក្រ ចំណូល សមត្ថភាព និងការប្រកួតប្រជែងចំពោះរដ្ឋាភិបាលជាតិកម្ពុជា ។ អនុសាសន៏ទាំងនោះរួមមានៈ

១. លៃលក ឬ បែងចែកថវិកាសម្រាប់គាំទ្រសេវាកម្មសំខាន់ៗ ជាពិសេសគឺ ការស្រោចស្រព និងឥណទាន

២. ផ្តល់ព័ត៌មានទីផ្សារសម្រាប់កសិករក្រីក្រ ដើម្បីអោយពួកគាត់ទទួលបានតម្លៃល្អប្រសើរសម្រាប់ផលិតផលរបស់ពួកគាត់

៣. ពង្រីកការគាំទ្រកម្មវិធីពង្រឹងសមត្ថភាព និងកម្មវិធីបណ្តុះបណ្តាលក្នុងផ្នែកផលិតកម្មកសិកម្ម និងដំណើរការទីផ្សារដល់កសិករក្រីក្រ រួមទាំងយុវជនជនបទផងដែរ

៤. ផ្តល់ទីកន្លែងសម្រាប់កសិករអាចចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការប្តេជ្ញាចិត្តចំពោះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

៥. ជំរុញបច្ចេកវិជ្ជាកសិកម្មនិរន្តភាព ជាមួយនឹងចង់លប់បំបាត់នូវវិធីសាស្ត្រធ្វើកសិកម្មដែលផ្អែកលើការប្រើប្រាស់សារធាតុគីមីដែលធ្វើអោយខូចប្រយោជន៍ចំពោះសុខភាពកសិករ និងរួមទាំងស្ត្រី និងកុមារ

៦. បង្កើនសារពើពន្ធរដ្ឋាភិបាលនៅក្នុងទីផ្សារស្រូវតាមរយៈការបង្កើតឃ្លាំងស្តុកស្រូវរបស់រដ្ឋ និងសន្យាគាំទ្រលើតម្លៃស្រូវសម្រាប់កសិករក្រីក្រ

យើងក៏ឃើញផងដែរនូវគោលនយោបាយពាណិជ្ជកម្មជាតិដែលមានតុល្យភាពប្រកបដោយប្រសិទ្ធភាពនៃផលប្រយោជន៏ពាណិជ្ជកម្ម។ ម៉្យាងវិញទៀត យើងទទូចសូមអោយរាជរដ្ឋាភិបាលកម្ពុជាការពារភាពប្រែ-ប្រួលសេដ្ឋកិច្ចរបស់កសិករក្រីក្រតាមរយៈការទទួលយកនូវគោលនយោបាយពាណិជ្ជកម្មដូចខាងក្រោមនេះ:

- ប្រឆាំងនឹងការនាំចូលផលិតផលដែលផលិតគ្រប់គ្រាន់ក្នុងស្រុកសម្រាប់ផ្គត់ផ្គង់ក្នុងប្រទេសកម្ពុជា
- ប្រឆាំងចំពោះការនាំចូលផលិតផលដែលគំរាមកំហែងសុខភាពអ្នកផលិត និងអ្នកបរិភោគក្នុងប្រទេសកម្ពុជាដូចជា សំភារៈប្រើប្រាស់កសិកម្មមានផ្ទុកសារធាតុគីមី, ជារី, ...
- ជម្រុញការប្រើប្រាស់ផលិតផលដែលផលិតបានក្នុងមូលដ្ឋាន ក្នុងទីផ្សារក្នុងស្រុក

ទោះបីជាចំណែកនៃវិស័យកសិកម្មនៅក្នុងលទ្ធផលសេដ្ឋកិច្ចសរុបរបស់សមាជិកអាស៊ាន ពិតជាមានការថយចុះយ៉ាងណា ក៏វានៅតែជាផ្នែកដ៏សំខាន់របស់សេដ្ឋកិច្ចប្រទេសទាំងនេះ ។ ឧទាហរណ៏ នៅប្រទេសកម្ពុជា ៧៨.១ ភាគរយ នៃចំណូលបានមកពីកសិកម្ម ។ ដូច្នេះហើយ យើងទទូចសូមអោយរដ្ឋាភិបាលកម្ពុជាដែលជាសមាជិកអាស៊ាន ជម្រុញការរៀបចំកិច្ចសហការពាណិជ្ជកម្មថ្នាក់តំបន់ដែលគាំទ្រនិងធ្វើអោយមាននិរន្តរភាពកសិកម្ម និងអ្នកផលិតផលិតផលកសិកម្មខ្នាតតូច ។ ដោយឡែក យើងស្នើអោយរដ្ឋាភិបាលកម្ពុជាផ្តល់អានុសាសន៏ចំពោះវិធានការដែលបានអនុម័តនៅក្នុងអាស៊ាន ដូចខាងក្រោមនេះ:

ក.កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវតែផ្តល់អោយប្រទេសនីមួយៗនូវភាពបត់បែនគ្រប់គ្រាន់ដើម្បីការពារផ្នែកដែលងាយខូចខាតដោយពាណិជ្ជកម្មសេរី

ខ.កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីត្រូវតែមានការការពារជាពិសេស និងភាពខុសគ្នា សម្រាប់ការពារប្រទេសងាយរងគ្រោះដូចប្រទេសកម្ពុជាអោយផុតពីផលដែលអាចកើតមាននៃការបើកទីផ្សារសម្រាប់កសិករក្រីក្រ

គ.អាស៊ានត្រូវតែបង្កើតមូលនិធិអភិវឌ្ឍន៏កសិកម្មរួមមួយដែលនឹងត្រូវប្រើគាំទ្រកម្មវិធីសំដៅចំពោះការអភិវឌ្ឍន៏វិស័យកសិកម្មរបស់សមាជិក។ គំរោងនេះអាចផ្តល់ឳកាសសម្រាប់បង្កើន ឬ ពង្រឹងផលិតភាពកសិកម្ម ទស្សនៈកិច្ចសិក្សា ការចែករំលែកបទពិសោធន៏ និងពត៌មានទីផ្សាររបស់កសិករនៅក្នុងតំបន់ និងពីតំបន់ផ្សេងៗទៀត

ឃ.អាស៊ាន ត្រូវតែចាប់ផ្តើមអភិវឌ្ឍន៏នូវស្តង់ដា អេសភីអេស ផ្ទាល់ខ្លួន ដែលការពារសុខភាពរបស់អ្នកបរិភោគ និងអ្នកផលិត

ង. អាស៊ានត្រូវតែបង្កើត ការស្តុកស្រូវបម្រុង ទ្រង់ទ្រាយធំថ្នាក់តំបន់ នឹងគ្រប់គ្រងដោយអង្គការតំណាងដោយ សមាជិអាស៊ាន។ ស្រូវបម្រុងមានបំណងជួយធានានូវសន្តិសុខស្បៀង ។